ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ ១២៧៨ សរណប.ស្ល

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ១២ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន អាជីវករ ឬម្ចាស់ក្រុមហ៊ុន ពាក់ព័ន្ធនឹងការផលិត និងការនាំចូលថង់ប្លាស្ទិកឱ្យបានជ្រាបថា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ ស្ថាប័នមានសមត្ថកិច្ចនឹងចាប់ផ្តើមពង្រឹងការត្រួតពិនិត្យការនាំចូល ការផលិត និងការចែកចាយថង់ប្លាស្ទិកស្តើងមានដៃយួរ ស្របតាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។ ដូច្នេះ ក្រសួងបរិស្ថាន សូមធ្វើការបញ្ជាក់ជូននូវលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

១. ថង់ប្លាស្ទិកស្តើងមានដៃយួរ ដែលអនុញ្ញាតឱ្យធ្វើការនាំចូល ផលិត ចែកចាយ និងប្រើប្រាស់ ត្រូវមាន កម្រាស់ចាប់ពី ០,០៣ មីល្លីម៉ែត្រឡើងទៅ និងមានរង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ សង់ទីម៉ែត្រ ឬ ១០ អ៊ីងឡើងទៅ។ ចំពោះថង់ប្លាស្ទិកស្តើងមានដៃយួរ ដែលមានកម្រាស់ និងទទឹងផ្នែកបាត មិនឆ្លើយតបនឹងការកំណត់នេះ ត្រូវបានហាមឃាត់ក្នុងការនាំចូល ផលិត ចែកចាយ និងប្រើប្រាស់។

២. រាល់ការនាំចូល និងការផលិតក្នុងស្រុកនូវថង់ប្លាស្ទិកស្តើងមានដៃយួរដែលមានកម្រាស់ និងទំហំទទឹងបាតស្របតាមការកំណត់ក្នុងចំណុច (១)ខាងលើ ត្រូវគោរពតាមបែបបទនិងនីតិវិធីជាធរមាន។

៣. ការនាំចូល និងការផលិតក្នុងស្រុកនូវថង់ប្លាស្ទិកស្តើងមានដៃយួរដែលមានកម្រាស់ និងទំហំទទឹងបាតស្របតាមការកំណត់ក្នុងចំណុច (១)ខាងលើ ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន លើកលែងតែការនាំចូលក្នុងបរិមាណតិចជាង ១០០គីឡូក្រាម។ សម្រាប់ការនាំចូល នៅលើសំបកវេចខ្ចប់ទំនិញថង់ប្លាស្ទិកត្រូវមានបញ្ជាក់ពីកម្រាស់ និងទំហំទទឹងបាតថង់ ហើយអាជីវករ ឬម្ចាស់ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំនាំចូលមកក្រសួងបរិស្ថាន ដោយភ្ជាប់នូវឯកសារថតចម្លងមានបោះត្រាក្រុមហ៊ុន ដូចខាងក្រោម ៖

ក. វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
ខ. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម)
គ. ប័ណ្ណពន្ធប៉ាតង់
ឃ. វិក័យប័ត្រនិងបញ្ជីវេចខ្ចប់ (មានបញ្ជាក់ពីកម្រាស់ និងទំហំទទឹងបាតថង់ប្លាស្ទិក)

៤. ការផ្តល់ថង់ប្លាស្ទិកស្តើងមានដៃយួរដល់អតិថិជននៅតាមបណ្តាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងផ្សារទំនើបនឹងត្រូវគិតកម្រៃបន្ថែម ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ តទៅ។

ក្រសួងបរិស្ថាន សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថាអាជីវករ ឬម្ចាស់ក្រុមហ៊ុន និងសាធារណជន ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

អាគារមរតកតេជោ ជីឡូលេខ503 ផ្លូវតេជោស៊ិអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004/023 235 006